NCAC

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទៃកពាណិជ្ជកម្ម

NATIONAL COMMERCIAL ARBITRATION CENTRE

# វិធានស្តីពី លក្ខណសម្បត្តិ និង ការចុះបញ្ជីសន្ធានការី

១៨ មីនា ២០២៣


គាំទ្រដោយ

IFC International Finance Corporation
WORLD BANK GROUP
*Creating Markets, Creating Opportunities*

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Confederation

Federal Department of Economic Affairs,
Education and Research EAER
**State Secretariat for Economic Affairs SECO**

# វិធានស្ដីពីលក្ខណសម្បត្តិ និងការចុះបញ្ជីសន្ធានការី

## ប្រការ ១. គោលបំណង

គោលបំណងនៃវិធានស្ដីពីលក្ខណសម្បត្តិ និងការចុះបញ្ជីសន្ធានការីរបស់ ម.ជ.ម. ("**វិធាន**") គឺផ្ដល់ជូនគូភាគីនូវបញ្ជីសន្ធានការី ដែលបំពេញលក្ខណសម្បត្តិអប្បបរមា ដើម្បីចុះបញ្ជីនៅក្នុងបញ្ជីសន្ធានការីរបស់ ម.ជ.ម. (សន្ធានការី ដែលបានបំពេញលក្ខខណ្ឌនេះហៅថា "**សន្ធានការីចុះបញ្ជី**")។

## ប្រការ ២. លក្ខណសម្បត្តិរបស់សន្ធានការី

២.១ លក្ខណសម្បត្តិសម្រាប់ចុះបញ្ជីជាសន្ធានការីក្នុងបញ្ជីសន្ធានការីរបស់ ម.ជ.ម. ("**បញ្ជីសន្ធានការី**") មានដូចខាងក្រោម៖

(ក) មានអាយុយ៉ាងតិច ៣០ (សាមសិប) ឆ្នាំ ឬមានបទពិសោធន៍យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ នៅក្នុងវិស័យធុរៈកិច្ច ឬការងារវិជ្ជាជីវៈ

(ខ) មានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ដែលបញ្ចប់ពីមហាវិទ្យាល័យណាមួយក្នុងប្រទេសកម្ពុជា ឬនៅបរទេស ។

(គ) បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្សេងៗផ្នែកសន្ទានកម្មពាណិជ្ជកម្ម ដែលរៀបចំដោយ ម.ជ.ម. ឬវគ្គបណ្តុះបណ្តាលដែលរៀបចំដោយស្ថាប័នវិជ្ជាជីវៈសន្ទានកម្មផ្នែកពាណិជ្ជកម្មណាមួយដែលទទួលស្គាល់ដោយ ម.ជ.ម. និង

(ឃ) បានប្រឡងជាប់ការប្រឡងដើម្បីបានការទទួលស្គាល់គុណវុឌ្ឍិ ដែលរៀបចំដោយ ម.ជ.ម. ឬដោយស្ថាប័នវិជ្ជាជីវៈសន្ទានកម្មផ្នែកពាណិជ្ជកម្មណាមួយ ដែលត្រូវបានទទួលស្គាល់ដោយ ម.ជ.ម.។

២.២ សន្ទានការីមិនត្រូវ៖

(ក) ជាមន្ត្រីរាជការ ឬស្ថិតក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ ឬតុលាការ។

(ខ) មានការកើតឡើង ឬជាប់ពាក់ព័ន្ធនូវករណីណាមួយដែលបានកំណត់នៅក្នុងប្រការ ៥ ខាងក្រោម។

## ប្រការ ៣. ការចុះបញ្ជីជាសន្ទានការី

៣.១ បេក្ខជនត្រូវដាក់ពាក្យសុំពេញលេញ ព្រមជាមួយព័ត៌មានលម្អិតសម្រាប់ការទាក់ទងជូនទៅ ម.ជ.ម. ដោយប្រើប្រាស់ទម្រង់ពាក្យសុំចុះបញ្ជីជាសន្ទានការីរបស់ ម.ជ.ម. ព្រមជាមួយឯកសារផ្សេងៗ ដែលបង្ហាញថាបេក្ខជនបានបំពេញលក្ខណសម្បត្តិដែលបានរៀបរាប់ខាងលើ និងភស្តុតាងនៃការបង់ប្រាក់កម្រៃសេវានៃការដាក់ពាក្យសុំ ដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម.។

៣.២ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការដាក់ពាក្យសុំពេញលេញរួចមក គណៈកម្មាធិការសមាជិកភាព ម.ជ.ម. នឹងពិនិត្យមើលពាក្យសុំ បន្ទាប់មកបញ្ជូនយោបល់របស់ខ្លួនទៅក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ដើម្បីសម្រេចចុងក្រោយ។ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ត្រូវសម្រេច និងជូនដំណឹងដល់បេក្ខជនជាលាយលក្ខណ៍អក្សរអំពីការសម្រេចរបស់ខ្លួនចំពោះពាក្យសុំចុះបញ្ជីនេះ ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលពាក្យសុំនោះ។ ប្រសិនបើចាំបាច់ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. អាចពន្យារពេលរហូតដល់ ១២០ (មួយរយម្ភៃ) ថ្ងៃប្រតិទិនបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំដើម្បីផ្តល់ដំណឹងដល់បេក្ខជន ថាតើបេក្ខជននោះបានបំពេញលក្ខណសម្បត្តិដែរឬទេ។

៣.៣ ប្រសិនបើបេក្ខជនមិនបំពេញលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជីទេនោះ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ត្រូវជូនដំណឹងដោយភ្ជាប់មូលហេតុទៅបេក្ខជនអំពីបញ្ហានេះ និងទុករយៈពេល ៣០ (សាមសិប) ថ្ងៃប្រតិទិនសម្រាប់ឱ្យបេក្ខជនផ្តល់ឯកសារបន្ថែមដើម្បីបង្ហាញថាបេក្ខជនពិតជាមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចដែលតម្រូវសម្រាប់ការចុះបញ្ជីនោះមែន។ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលឯកសារទាំងនោះ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ត្រូវផ្តល់ដំណឹងដល់បេក្ខជនអំពីសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន។

៣.៤ សេចក្តីសម្រេចចុះបញ្ជីជាសន្ធានការីក្នុងបញ្ជីសន្ធានការីនោះគឺជាឆន្ទានុសិទ្ធិរបស់ ម.ជ.ម.។ នេះគឺជាសេចក្តីសម្រេចមួយដែលធ្វើការពិចារណាទៅលើចំនួនសន្ធានការីដែលមានក្នុងបញ្ជី ប្រភេទសំណុំរឿងផ្សេងៗដែលបានដាក់មក ម.ជ.ម. ភាពចម្រុះ និងវិស័យផ្សេងៗដែលកំពុងមានតម្រូវការ។

៣.៥ ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. សម្រេចថាបេក្ខជនបំពេញតាមលក្ខណសម្បត្តិ អគ្គលេខាធិការ នឹងជូនដំណឹងទៅបេក្ខជន ដើម្បីឱ្យបេក្ខជនធ្វើការបង់ភាគទានប្រចាំឆ្នាំគ្រប់ចំនួនដែលត្រូវអនុវត្តចំពោះសន្ធានការីចុះបញ្ជីនៅ ម.ជ.ម.។ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ត្រូវធានាថាអគ្គលេខាធិការដ្ឋានចុះបញ្ជីបេក្ខជនជាសន្ធានការីក្នុងបញ្ជីសន្ធានការី ដោយមានអានុភាពចាប់ពីថ្ងៃទីមួយនៃខែបន្ទាប់ ក្រោយពីបានទទួលការបង់ភាគទានរហូតដល់ និងរួមបញ្ចូលថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែល។ អគ្គលេខាធិការដ្ឋាន ត្រូវជូនដំណឹងដល់បេក្ខជនអំពីការចុះបញ្ជីនេះ។

៣.៦ មានតែសន្ធានការីដែលបានចុះបញ្ជីនៅក្នុងបញ្ជីសន្ធានការីរបស់ ម.ជ.ម. ប៉ុណ្ណោះដែលទទួលបានសិទ្ធិប្រើប្រាស់ងារជា "**សន្ធានការីចុះបញ្ជីនៅ ម.ជ.ម.**"។ ក្នុងករណីដែលសន្ធានការីដែលបានចុះបញ្ជីនៅ ម.ជ.ម. ខកខានក្នុងការបំពេញលក្ខខណ្ឌរបស់ ម.ជ.ម. សម្រាប់ការចុះឈ្មោះ ការប្រើប្រាស់ងារជាសន្ធានការីចុះបញ្ជីនៅ ម.ជ.ម. នឹងត្រូវបានបញ្ចប់ ហើយព័ត៌មានអំពីប្រវត្តិរូបរបស់សន្ធានការីនឹងលែងមាននៅលើគេហទំព័ររបស់ ម.ជ.ម.។

## ប្រការ ៤. ការចុះបញ្ជីសន្ធានការីបន្តសារជាថ្មី

នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះពាក្យសុំសម្រាប់ចុះបញ្ជីបន្តសារជាថ្មីប្រចាំឆ្នាំរបស់សន្ធានការីចុះបញ្ជីនៅក្នុងបញ្ជីសន្ធានការី៖

៤.១ ក្រោយពីការទទួលបានការបង់ភាគទានប្រចាំឆ្នាំហើយ ម.ជ.ម. ត្រូវចុះបញ្ជីសារជាថ្មីនៃសន្ធានការីចុះបញ្ជីសម្រាប់ឆ្នាំក្រោយ លើកលែងតែ៖

(ក) សន្ធានការីចុះបញ្ជីបានជូនដំណឹងដល់ ម.ជ.ម. ថាខ្លួនមិនមានបំណងចុះបញ្ជីសារជាថ្មីជាសន្ធានការីចុះបញ្ជី។

(ខ) មានករណីមួយ ឬច្រើនដែលបានកំណត់ក្នុងប្រការ ៥ ខាងក្រោមកើតឡើង ឬជាប់ពាក់ព័ន្ធនឹងសន្ធានការីចុះបញ្ជី ឬ

(គ) សន្ធានការីចុះបញ្ជីខកខានមិនបានដាក់សេចក្តីប្រកាសផ្ទាល់ខ្លួនក្នុងទម្រង់ ដែលកំណត់ដោយ ម.ជ.ម. និងឯកសារផ្សេងទៀតដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ដើម្បីបញ្ជាក់ថាខ្លួននៅតែបំពេញលក្ខណសម្បត្តិ និងលក្ខខណ្ឌតម្រូវនានានៃវិធាននេះ។

៤.២ ប្រសិនបើព័ត៌មានដែល ម.ជ.ម. មានការកត់ត្រាទុកមិនមានភាពច្បាស់លាស់ ឬមិនគ្រប់គ្រាន់ ម.ជ.ម. អាចតម្រូវឱ្យសន្ធានការីចុះបញ្ជីផ្តល់ព័ត៌មានបន្ថែម។ សន្ធានការីចុះបញ្ជីត្រូវឆ្លើយតបក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹង។

៤.៣ ប្រសិនបើសន្ធានការីចុះបញ្ជី មិនបំពេញតាមលក្ខណសម្បត្តិដែលបានតម្រូវសម្រាប់ការចុះបញ្ជីបន្តសារជាថ្មីដែលបានរៀបរាប់ខាងលើនោះទេ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. មិនត្រូវបន្តចុះបញ្ជីសារជាថ្មីឱ្យសន្ធានការីនោះទេ។ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ត្រូវផ្តល់ដំណឹងភ្ជាប់ជាមួយមូលហេតុដល់សន្ធានការីចុះបញ្ជីនោះ។ សន្ធានការីចុះបញ្ជីត្រូវមានរយៈពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ដើម្បីបញ្ជាក់ជាលាយលក្ខណ៍អក្សរ និងបញ្ជូនឯកសារនានាដែលបង្ហាញពីមូលដ្ឋានសម្រាប់ការចុះបញ្ជីត្រូវបានបន្តសារជាថ្មីសម្រាប់ឆ្នាំបន្ទាប់។ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលឯកសារទាំងនោះ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ត្រូវជូនដំណឹងដល់បេក្ខជនអំពីសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន។

៤.៤ ប្រសិនបើស្របតាមនីតិវិធីនៃប្រការនេះ សន្ធានការីចុះបញ្ជីបំពេញតាមលក្ខណសម្បត្តិតម្រូវសម្រាប់ការចុះបញ្ជីបន្តសារជាថ្មី អគ្គលេខាធិការដ្ឋានត្រូវផ្ញើវិក្កយបត្របង់ភាគទានប្រចាំឆ្នាំសម្រាប់ឆ្នាំដែលចុះបញ្ជីបន្តសារថ្មីនោះ ទៅសន្ធានការីចុះបញ្ជី។ បន្ទាប់ពីទទួលបានការបង់ភាគទានប្រចាំឆ្នាំគ្រប់ចំនួន សម្រាប់ឆ្នាំដែលត្រូវបានចុះបញ្ជីបន្តសារជាថ្មីនោះហើយ ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ត្រូវធានាថា អគ្គលេខាធិការដ្ឋានចុះបញ្ជីបន្តសារជាថ្មីនៃសន្ធានការីដែលបានចុះបញ្ជីដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា នៃឆ្នាំដែលមានការចុះបញ្ជីបន្តសារជាថ្មីនោះ។

## ប្រការ ៥. ការលុបឈ្មោះសន្ទានការីចុះបញ្ជី

ក្រុមប្រឹក្សាប្រតិបត្តិ ម.ជ.ម. ត្រូវលុបឈ្មោះសន្ទានការីចេញពីបញ្ជី ប្រសិនបើបុគ្គលនោះ៖

(ក) ក្លាយជាអសមត្ថជនផ្នែករូបរាងកាយ ឬសតិស្មារតី មិនអាចបំពេញតួនាទីរបស់ខ្លួនបាន

(ខ) ត្រូវបានប្រកាសថាក្ស័យធន ឬត្រូវបានដាក់ឱ្យស្ថិតនៅក្រោមដំណើរការនៃការជម្រះបញ្ជី

(គ) ដាក់ពាក្យលាលែងជាលាយលក្ខណ៍អក្សរទៅកាន់ ម.ជ.ម.

(ឃ) ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

(ង) បំពានលើក្រមសីលធម៌សម្រាប់សន្ទានការី របស់ ម.ជ.ម. ឬវិធានផ្សេងទៀតរបស់ ម.ជ.ម.

(ច) បំពានលើភារកិច្ចរក្សាការសម្ងាត់ដែលខ្លួនមានចំពោះ ម.ជ.ម.

(ឆ) ធ្វើសកម្មភាព ឬមានជាប់ពាក់ព័ន្ធនឹងបញ្ហាហិរញ្ញវត្ថុ នយោបាយ ច្បាប់ ឬសង្គម ដែលអាចនាំឱ្យអាប់ឱន ឬប៉ះពាល់ដល់សុចរិតភាពរបស់ ម.ជ.ម.

(ជ) ទទួលមរណភាព ឬ

(ឈ) ខកខានមិនបានបង់ភាគទានប្រចាំឆ្នាំដោយគ្មានមូលហេតុត្រឹមត្រូវ ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានវិក្កយបត្របង់ភាគទាន។

## ប្រការ ៦. អវសានប្បញ្ញត្តិ

៦.១ វិធាននេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់ ម.ជ.ម. នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣។

៦.២ វិធាននេះមានអានុភាពអនុវត្តចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ តទៅ។

ថ្ងៃសៅរ៍ ១២ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

**ប្រធាន**

**សាន គីរី**

WWW.NCAC.ORG.KH